# ប្រព័ន្ធកសិកម្មចម្រុះ រវាងការចិញ្ចឹមគោ មាន់ ការដាំដំឡូងមី ដំឡូងដៃខ្លា សណ្តែកគួរ និងត្រសក់

## ១. និយមន័យ

ប្រព័ន្ធកសិកម្មចម្រុះ **រវាងការចិញ្ចឹមគោ មាន់ ការដាំដំឡូងមី ដំឡូងដៃខ្លា សណ្តែក គួរ និងត្រសក់** គឺជាការធ្វើកសិកម្មច្រើនប្រភេទ ដែលដាំលើផ្ទៃដីជុំវិញផ្ទះ និងចម្រុះគ្នា ទៅតាមទំហំដីតូចធំ នៅតាមគេហដ្ឋានរបស់កសិករ។ ប្រព័ន្ធនេះបានដើរតួរយ៉ាងសំខាន់ និងបំពេញមុខងារឲ្យគ្នាទៅវិញទៅមកជាប្រចាំ។ ការចិញ្ចឹមគោ និងមាន់ គឺយើងអាចប្រមូលលាមក និងសម្រាមបង្កើតបានជាជីសម្រាប់ដាក់ដំណាំដំឡូង

សណ្តែកគួរ ត្រសក់ និងបង្កើនគុណភាពដីកុំឲ្យរឹង និងការពារការបាត់បង់ ជីវសាស្រ្តក្នុងដី។ ចំណែកការដាំដំឡូងមី ដំឡូងដៃខ្លា ត្រសក់ និងសណ្តែកគួរ វាអាចធ្វើជាំណីមាន់ គោ និងធ្វើឲ្យដីមានអន្តរអំពើជាមួយដំណាំ។

## ២. ការរៀបចំប្លង់

តាមរយៈការសិក្សា និងការចុះសង្កេតជាមួយកសិករឃើញថា ការអនុវត្តន៍ប្រព័ន្ធកសិកម្មចម្រុះបែបនេះមានប្រមាណ ១០ ភាគរយដែលអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ជាទូទៅនៅក្នុងភូមិមាន ១០៦ គ្រួសារ ហើយមានគ្រួសារប្រមាណ ១០ គ្រួសារដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ធាតុសំខាន់នៃប្រព័ន្ធនេះរួមមាន ការចិញ្ចឹមសត្វ ឈើហូបផ្លែ ដំណាំ និងការដាំបន្លែ និងជាពិសេសប្រព័ន្ធទឹក។

- ទំហំដីលំនៅដ្ឋានមានចាប់ពី ៣០០ ម៉ែត្រការ៉េឡើងទៅ រហូតដល់ដល់ ២ ហិចតាដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ពួកគាត់បានអនុត្តន៍ប្រព័ន្ធកសិកម្មបែបនេះ ដើម្បីផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ និងលក់ទៅទីផ្សារខាងក្រៅ

- មាន់ មានចាប់ពី មេ ៣ក្បាល និងបា ១ក្បាល ឡើងទៅ ដោយចិញ្ចឹមបែបលក្ខណៈប្រពៃណី ដោយប្រើពូជក្នុងស្រុក ហើយជាន់ឈាមគ្នា បណ្តាលឲ្យមាន់មានលកខណៈធំធាត់យឺត និងសំបូរកើតជំងឺច្រើនដូចជា អុត អាសន្នរោគ និងញូកាស ដោយមិនបានប្រើប្រាស់វ៉ាក់សាំង និងថ្នាំព្យាបាលការ
ពារ។ ការផ្តល់ចំណីវិញគឺបាចអង្ករ រីស្រូវ និងការប្រលែងពាសវាលពាសកាល រកស៊ីដោយខ្លួនវា។ ការការចីញ្ចឹមមាន់របស់ពួកគាត់ គឺគ្រាន់តែបានធ្វើជាម្ហូបអាហារ និងលក់បានតិចតួច ដោយចំណាយពេលរហូត ៦ ទៅ ៦ ខែ ក្នុងការចិញ្ចឹមមាន់។



- គោ គេចាប់ចិញ្ចឹមចាប់ពី ២ក្បាល រហូតដល់ ១៥ ក្បាល ដោយចិញ្ចឹមគោមានទីផ្សារល្អ នៅតំបន់នេះមានតំលៃខ្ពស់គួរសម អាចលក់ និងជួយផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ ហើយជាពិសេសលាមកវាអាចធ្វើជាជីដាក់ដំណាំផ្សេងៗ និងកាត់បន្ថយការទិញជីគីមីផងដែរ

- ដំឡូងមី មានផ្ទៃដីចាប់ពី ២០០ ម៉ែត្រការ៉េឡើងទៅរហូតដល់ ៥០០ ម៉ែត្រការ៉េ ការដាំដំឡូងមីវាជាផ្នែកមួយសម្រាប់ធ្វើជាអាហារសម្រាប់សត្វ មនុស្ស និងអាចលក់ទៅលើទីផ្សារក្នុងតបន់ និងជាពិសេសដំណាំងាយស្រួលដាំ ធន់នឹងភាពរាំងស្ងួត ត្រូវការទឹកតិច



- ដំឡូងដៃខ្លា មានផ្ទៃដីចាប់ពី ២០០ ម៉ែត្រការ៉េឡើងទៅរហូតដល់ ១០០០ ម៉ែត្រការ៉េ ការដាំដំឡូងដៃខ្លាវាជាផ្នែកមួយសម្រាប់ធ្វើជាអាហារសម្រាប់សត្វមនុស្ស និងអាចលក់ទៅលើទីផ្សារតម្លៃខ្ពស់ក្នុងតបន់ (២០០០រៀល/គីឡូក្រាម) និងជាពិសេសដំណាំងាយស្រួលដាំ ធន់នឹងភាពរាំងស្ងួត ត្រូវការទឹកតិច

- សណ្តែកគួរ មានផ្ទៃដីដាំចាប់ពី ៥០ ម៉ែត្រការ៉េ រហូតដល់ ៣០០ ម៉ែត្រការ៉េ គឺគេដាំដើម្បីផ្គត់ផ្គង់សម្រាប់ជាអាហារប្រចាំថ្ងៃ និងបានលក់តិចតួច ដោយសារតំបន់នេះមិនសូវមានទីផ្សារ សណ្តែកគួរ ហើយជាពិសេសសំបូរសត្វល្អិតបំផ្លាញ

ដោយរោម រួចស្លឹក ខ្វះទឹកជាដើម។ វាជាប្រភេទដំណាំដែលត្រូវការទឹកច្រើន បច្ចេកទេស និងពេលវេលាថែទាំវាជាប្រចាំ



- ត្រសក់ មានកសិករនិយមដាំច្រើនជាងគេ ដែលមានផ្ទៃដាំចាប់ពី ២០០ ម៉ែត្រការ៉េ រហូតដល់ ៥០០ ម៉ែត្រការ៉េ។ វាជាប្រដំណាំដែលមានអាយុខ្លី ទិន្នផលច្រើន ដាំបានទាំងខែប្រាំង និងវស្សា ដែលមានតំលៃទីផ្សារខ្ពស់ និងងាយស្រួលលក់ ដែលអាចឲ្យប្រជាកសិករមួយចំនួនអាចរកប្រាក់ចំណូលបានច្រើនពីវា ក្នុងមួយថ្ងៃចន្លោះពី ៥០ គីឡូ ទៅ ១០០ គីឡូក្រាមក្នុមួយថ្ងៃប៉ុន្តែចាំបាច់កសិករត្រូវចេះបច្ចេកទេស និងមានប្រព័ន្ធទឹកស្រោចស្រព្វគ្រប់គ្រាន់។



## ៣. គុណសម្បត្តិ

- បង្កើនសេដ្ឋកិច្ចគ្រួសារ កាត់បន្ថយការលក់កំលាំងពលកម្មនិង ការចំណាកស្រុក
- បង្កើតឲ្យមានមីក្រូអាកាសធាតុល្អនៅក្នុងដីលំនៅដ្ឋាន មានម្លប់សម្រាប់សត្វ
- មិនទុកដីឲ្យទំនេរ ងាកមកដាំដំណាំដែលមានផលប្រយោជន៍សម្រាប់គ្រួសារ
- ងាយស្រួលក្នុងការការប្រមូលសម្រាម និងផលិតជីធម្មជាតិសម្រាប់ដាក់ដំណាំ បង្កើនជីជាតិជាតិដី កាត់បន្ថយការប្រើប្រាស់ជីគីមី

- កាត់បន្ថយការចំណាយទិញស្បៀង ( ផ្លែឈើ សាច់...) ពីទីផ្សារនិងទទួលបានប្រាក់ចំណូលពីការលក់ ផលិតផលទៅទីផ្សារ។
- ផលិតផលកសិកម្មមានសុវត្ថិភាព និងគុណភាព ងាយស្រួលលក់។

## ៤. គុណវិបត្តិ

ការធ្វើប្រព័ន្ធកសិកម្មចម្រុះបែបនេះទាមទាឲ្យកសិករ មានកការតាំងចិត្ត ឧស្សាហ៍ព្យាយាម ពេលវេលា កំលាំងពលកម្ម សម្រាប់មើលថែគ្រប់គ្រង និងដើមទុនច្រើនសម្រាប់បង្កើតវា។

- ចំណាយដើមទុនច្រើន កំលាំងពលកម្មច្រើន ពេលវេលាយូរអង្វែងសម្រាប់គ្រប់គ្រងមើលថែវា
- តម្រូវការប្រើប្រាស់ទឹកច្រើនពេញមួយឆ្នាំ
- ពិបាកគ្រប់គ្រងកសិដ្ឋាន នៅពេលមានបញ្ហាសត្វល្អិតបំផ្លាញ និងជំងឺចូល
- ត្រូវការប្រើប្រាស់សម្ភារៈ និងគ្រាប់ពូជអស់ច្រើន
- ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីអស់ច្រើន។

## ៥. អនុសាសន៍ ឬចំណុចកែលម្អ

ខាងក្រោមនេះ គឺជាអនុសាសន៍ ឬចំណុចកែលម្អ ដែលទទួលបានតាម រយៈការពិភាក្សាជាមួយកសិករ និងការចុះសង្កេតផ្ទាល់នៅក្នុងតំបន់គោលដៅរបស់គម្រោង SUCRA៖

- កសិករគួររៀបចំឲ្យមានប្លង់មេ សម្រាប់ការរៀបចំកសិដ្ឋានប្រព័ន្ធ កសិកម្មចម្រុះរវាងការធ្វើស្រែ ការចិញ្ចឹមត្រី ការដាំឈើហូបផ្លែ និងការចិញ្ចឹមមាន់
- កសិករត្រូវជ្រើសរើសពូជស្រូវ ដែលធន់និងការប្រែប្រួលអាកាសធាតុ
- បង្កើនចម្រុះភាពនៃដំណាំ រួមមានការដាំបន្លែ ដាំដើមឈើហូបផ្លែ ឈើពហុប្រយោជន៍ ដើម្បីបង្កើនភាពធន់ទៅនឹងការអាកាសធាតុ បង្កើនភាពធន់ទៅនឹងជម្ងឺនិងសត្វល្អិត ក៏ដូចជាមានអាហារូបត្ថម្ភ និងឱកាសទីផ្សារ
- ជ្រើសរើសដំណាំដែលមានតម្លៃទីផ្សារ ធន់ទៅនឹងអាកាសធាតុ និងមានអាហារូបត្ថម្ភសម្រាប់ធ្វើការដាំដុះបន្ថែម។ ចំពោះឈើហូបផ្លែកសិករគួរដាំបន្ថែមដូចជា៖ ក្រូចពោធិ៍សាត់ (ចំពោះគ្រួសារដែលមិនទាន់បាន ដាំ) ខ្នុរណាំងការ៉ុត ដូងក្រអូប ស្វាយកែវរមៀត ស្វាយខ្ទិះ ត្របែកគីឡូ។ ចំពោះដើមឈើពហុប្រយោជន៍កសិករគួរដាំដើមអង្កាញ់ កន្ទំថេត អង្គាដី សណ្ដែកអង្រៃ ស្ដៅ ម្រុំ បន្លែម (ដែលអាចធ្វើចំណីសត្វ ចំណីមនុស្ស ឱសថ ជី...)
- បើសិនជាកសិករមានទីធ្លាសមស្រប គួរតែជីកស្រះ ឬជីកប្រព័ន្ធចង្អូរ កូនប្រឡាយនៅជុំវិញដីលំនៅដ្ឋាន ដើម្បីងាយស្រួល ក្នុងការគ្រប់គ្រងទឹក។

៙៚៙

រៀបរៀងដោយ ៖ គម្រោងការពង្រឹកបច្ចេកទេសកសិកម្មដែលធន់នឹងអាកាសធាតុ ( SUCRA ) នៃកម្មវិធីASPIRE
ផលិតឆ្នាំ ៖ ២០២០